# សន្ធិសញ្ញាមិនស្មើភាព (Unequal Treaties)

សន្ធិសញ្ញាមិនស្មើភាព ត្រូវបានផ្តល់ន័យថា ជាសន្ធិសញ្ញា ដែលផ្ទៀងប្រយោជន៍ទៅរកភាគីម្ខាង មិនបង្កើតសិទ្ធិ និងកាតព្វកិច្ចទៅវិញទៅមក (reciprocal) រវាងភាគី។ ដូចនេះ វាបង្ហាញពីភាពផ្ទុយគ្នានឹងគោលការណ៍អធិបតេយ្យស្មើភាពគ្នា (Equal Sovereignty)។

សន្ធិសញ្ញាប្រភេទនេះ កើតមានច្រើនទៅក្នុងសម័យអាណានិគម។ សន្ធិសញ្ញារវាងជប៉ុននិងចិនជាឧទាហរណ៍មួយ។ សន្ធិសញ្ញាប្រភេទនេះ គ្រប់គ្រងដោយច្បាប់អន្តរជាតិ ឬខ្លះមិនត្រូវបានគ្រប់គ្រងដោយច្បាប់អន្តរជាតិទេ។ សន្ធិសញ្ញានោះ មានខ្លឹមសារ ដូចជា ការផ្តល់សម្បទានដល់ភាគីម្ខាង (Concession) និង ខអនុញ្ញាតឲ្យភាគីម្ខាងរួចផុតពីយុត្តាធិការរបស់តុលាការភាគីផ្សេងទៀត (Extraterritorial Rights)។ ក្រោយចុងបញ្ចប់នៃសង្គ្រាមលោកលើកទីមួយ ខ្លឹមសារនៃសន្ធិសញ្ញា ចាប់ផ្តើមកែសម្រួល ជាពិសេសសម្រាប់ចិន ដោយបានធ្វើឲ្យមានភាពប្រសើរឡើងដល់ចិន និង លុបចោលនូវសិទ្ធិមានក្រៅដែនដីរបស់ភាគីម្ខាង។ ជាលទ្ធផលផងដែរ រដ្ឋខ្លះបានចាប់ផ្តើមបដិសេធ លទ្ធផលនៃសន្ធិសញ្ញាមិនស្មើគ្នា ដូចជាការសុំកែប្រែបន្ទាត់ព្រំដែន។

ទោះបីក្រោយបញ្ចប់នឹមអាណានិគមក្តី សន្ធិសញ្ញាមិនស្មើភាព នៅតែកើតមាន ដូចជាសន្ធិសញ្ញាសន្តិភាពដែលបង្ខំឲ្យរដ្ឋចាញ់សង្គ្រាមព្រមទទួលយក។ ធម្មនុញ្ញអង្គការសហប្រជាជាតិ ក៏អាចត្រូវបានចាត់ថា ជាសន្ធិសញ្ញាមិនស្មើភាព ដោយសារ វាបានផ្តល់សិទ្ធិ និងអំណាចដល់សមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខ។

ក្នុងពេលនោះ រដ្ឋខ្លះ បានចាត់វាជាមូលដ្ឋាន ក្នុងការបដិសេធសុពលភាពនៃសន្ធិសញ្ញា។ ទោះបីជាយ៉ាងនេះក្តី វាមិនមែនជាមូលហេតុ ដែលត្រូវបានទទួលស្គាល់ក្នុងសន្ធិសញ្ញឆ្នាំ១៩៦៩ ស្តីពីសន្ធិសញ្ញាទេ។ រដ្ឋជាភាគី អាចលើកយកជាមូលដ្ឋាន ក្នុងការដកខ្លួន ឬផ្អាកការអនុវត្តសន្ធិសញ្ញាដែលពាក់ព័ន្ធ។ ខ្លឹមសារសន្ធិសញ្ញាមិនស្មើភាព ដែលមានវិការៈធ្ងន់ធ្ងរ ដូចជាការបង្ខំរដ្ឋ ដោយប្រើកម្លាំងទ័ព ក្នុងពេលអនុម័តសន្ធិសញ្ញាជាដើម អាចជាមូលហេតុនៃអសុពលភាព (Max Planck Encyclopedia of Public International Law, Unequal Treaties, pp. 1008-1011)។